វេទិកាអនាគត
FUTURE FORUM

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ការបើកបង្ហាញសក្តានុពល

## អត្ថប្រយោជន៍សេដ្ឋកិច្ចនៃសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ប្រទេសកម្ពុជា

ខែកុម្ភៈ ឆ្នាំ២០២៦

សន្លឹកព័ត៌មាន



## សារតា

**«សង្គមដែលបើកទូលាយ មានបរិយាបន្ន និងមានភាពចម្រុះ គឺមានភាពល្អប្រសើរសម្រាប់ធុរកិច្ច និងល្អប្រសើរសម្រាប់កំណើនសេដ្ឋកិច្ច។»** អូផេន ហ្វ័រ ប៊ិសនីស្ស (Open for Business)

សមភាពច្បាប់អាពាហ៍ពិពាហ៍គឺជាសេចក្តីបញ្ជាក់ដ៏សំខាន់មួយអំពីសិទ្ធិស្មើភាពគ្នា និងកិច្ចការពារចំពោះគ្រួសារ។ តាមបទពិសោធរបស់អន្តរជាតិចំនួនលើសពី៣៥ប្រទេស ដែលបានទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍រួចមកហើយនោះបានបង្ហាញថា វាក៏អាចជាចលករសម្រាប់ឱកាសសេដ្ឋកិច្ចផងដែរ។ បណ្តាប្រទេសដែលបានទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ អាចមើលឃើញពីភាពរឹងមាំនៃលទ្ធផលវិស័យទេសចរណ៍ជាងមុន ភាពល្អប្រសើរនៃបរិយាកាសវិនិយោគទុន គ្រួសារកាន់តែមានភាពធន់មានសុខភាពល្អជាងមុន និងកម្លាំងពលកម្មនៃផលិតភាពកើនឡើងផងដែរ។ កំណើននូវអត្ថប្រយោជន៍ទាំងនេះពុំមែនបានផ្តល់ឱ្យតែចំពោះសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានផ្តល់ឱ្យចំពោះសេដ្ឋកិច្ចដ៏ទូលំទូលាយផងដែរ។

**សមភាពច្បាប់អាពាហ៍ពិពាហ៍** សំដៅដល់ការទទួលស្គាល់អាពាហ៍ពិពាហ៍ស្របច្បាប់ពេញលេញរវាងបុគ្គលពីររូបមានភេទដូចគ្នា ដោយមានលក្ខខណ្ឌច្បាប់ដូចគ្នាទៅនឹងគូស្រករដែលមានភេទផ្ទុយគ្នាដែរ។

នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ គូស្រករភេទដូចគ្នាមិនអាចចុះសំបុត្រអាពាហ៍ពិពាហ៍ស្របតាមច្បាប់បានឡើយ។ ការទទួលបានសមភាពច្បាប់អាពាហ៍ពិពាហ៍ត្រូវបានកំណត់ដោយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដែលជាពលរដ្ឋកម្ពុជាថាជាអាទិភាពមួយដ៏ចាំបាច់ ដើម្បីធានាបាននូវការទទួលស្គាល់ស្មើភាពគ្នា ការការពារគ្រួសារ និងការរួមចំណែកដល់បរិយាបន្នសង្គម។

ប្រទេសកម្ពុជាស្ថិតនៅក្នុងខណៈពេលមួយដ៏សំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជាគាំទ្រសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នា និងការមិនរើសអើង។ ជាពិសេស រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនូវអនុសាសន៍ទាំងអស់ស្តីពីការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នា នៃយន្តការការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) នៅក្នុងឆ្នាំ២០២៤ ដែលក្នុងនោះមានអនុសាសន៍ចំនួនប្រាំពីរស្តីពីការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា។ ការគាំទ្ររបស់សាធារណជនកម្ពុជាចំពោះសមភាពច្បាប់អាពាហ៍ពិពាហ៍ក៏មានការកើនឡើងផងដែរ។

ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាកំពុងតែធ្វើដំណើរឆ្ពោះទៅរកមហិច្ឆតានៃការសម្រេចបាននូវទស្សនវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ ដែលស្របតាម**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (ឆ្នាំ២០២៣-២០២៨)** ដែលផ្តោតលើកំណើនសមធម៌ ប្រសិទ្ធភាព បរិយាបន្ន ចីរភាព និងភាពធន់។

**«គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាគឺមិនទុកនរណាម្នាក់ចោលឡើយ។ ចំពោះសង្គមជាតិទាំងមូល ដើម្បីការអភិវឌ្ឍ យើងត្រូវការប្រជាពលរដ្ឋគ្រប់រូបចូលរួម។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា គឺជាធនធានមនុស្សដែលអាចរួមចំណែកជួយប្រទេសជាតិ។»** នេះគឺជាការលើកឡើងរបស់ **ឯកឧត្តម កែវ រ៉េមី** ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

ការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ នឹងមានភាពស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (ឆ្នាំ២០២៣-២០២៨) របស់ប្រទេសកម្ពុជា។ សមភាពច្បាប់អាពាហ៍ពិពាហ៍ នឹងអាចជួយគាំទ្រឱ្យគ្រួសារមានស្ថិរភាព ពង្រឹង មូលធនមនុស្ស និងបង្ហាញសញ្ញាយ៉ាងច្បាស់លាស់មួយថា កម្ពុជាគឺជាប្រទេសដែលបើកចំហទូលាយ ទំនើបទាន់សម័យ មានការប្រកួតប្រជែង និងជាប្រទេសដែលត្រៀមខ្លួនរួចជាស្រេចនាពេលអនាគតក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរ វិនិយោគិន និងបុគ្គលដែលមានជំនាញទេពកោសល្យនៅលើសកលលោក ដែលជួយបង្កើននូវកិត្តិស័ព្ទជាតិ នៅខណៈពេលដែលធ្វើឱ្យមានភាពប្រសើរឡើងចំពោះសេចក្តីថ្លៃថ្នូរ និងឱកាសសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។

ការសិក្សាស្រាវជ្រាវនេះបង្ហាញពីរបៀបនៃ**ការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ ដែលមិនត្រឹមតែអាចនឹងបញ្ជាក់ពីសេចក្តីថ្លៃថ្នូរនិងសិទ្ធិស្មើភាពគ្នាសម្រាប់គ្រួសារទាំងអស់ប៉ុណ្ណោះទេ វាថែមទាំងរួមចំណែកអាចនឹងធ្វើឱ្យមានថាមវន្ត បរិយាបន្ន នវានុវត្តន៍ និងភាពធន់នៃសេដ្ឋកិច្ចកម្ពុជាច្រើនជាងមុនទៀតផងដែរ។**

វិធីសាស្ត្រ៖ ផ្អែកលើសេចក្តីសង្ខេបនៃរបាយការណ៍សិក្សាស្រាវជ្រាវទាំងមូល សន្លឹកព័ត៌មាននេះបង្ហាញពីសក្តានុពលអត្ថប្រយោជន៍សេដ្ឋកិច្ចនៃសមភាពច្បាប់អាពាហ៍ពិពាហ៍ ដែលបានទាញចេញមកពីភស្តុតាងនៃការសិក្សាស្រាវជ្រាវជាសកលនានា ទិន្នន័យរបស់ប្រទេសកម្ពុជា កិច្ចសម្ភាសអ្នកពាក់ព័ន្ធ និងគំរូនៃសេណារីយ៉ូចង្អុលបង្ហាញដោយបានយកមកអនុវត្តតាមវិធីសាស្ត្រដែលបានទទួលស្គាល់ពីអន្តរជាតិ។ តួលេខទាំងអស់បានគូសបញ្ជាក់ និងចង្អុលបង្ហាញពីទំហំសក្តានុពលនៃអានុភាព និងទិសដៅនៃអត្ថប្រយោជន៍សេដ្ឋកិច្ច។

សក្តានុពលអត្ថប្រយោជន៍សេដ្ឋកិច្ចនៃសមភាពច្បាប់អាពាហ៍ពិពាហ៍គឺមាននៅក្នុង៥វិស័យសំខាន់ៗខាងក្រោម៖

| ១.ការជំរុញវិស័យទេសចរណ៍ | ២.ការទាក់ទាញវិនិយោគទុន និងជំនាញទេពកោសល្យ | ៣.ការបង្កើនវិស័យឧស្សាហកម្មពិធីមង្គលការ | ៤.ការពង្រឹងគ្រួសារ | ៥.ការធ្វើឱ្យប្រសើរឡើងផ្នែកសុខភាព ផលិតភាព និងពាណិជ្ជកម្ម |
|---|---|---|---|---|

## ១.ការជំរុញវិស័យទេសចរណ៍

ទេសចរណ៍គឺវិស័យសេដ្ឋកិច្ចដ៏សំខាន់បំផុតមួយរបស់ប្រទេសកម្ពុជា ដែលបានផ្តល់ប្រាក់ចំណូល និងជួយឱ្យមានស្ថិរភាពជីវភាពរស់នៅ។ សមភាពច្បាប់អាពាហ៍ពិពាហ៍ផ្តល់ឱកាសក្នុងការពង្រឹងវិស័យនេះ។ តាមរយៈ**ការទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើង ការជួយជំរុញឱ្យមានការចំណាយច្រើនឡើង ការបង្កើតការងាររាប់ពាន់កន្លែង និងការបើកឱ្យមានទីផ្សារថ្មីៗនៅក្នុងតំបន់គោលដៅសម្រាប់ពិធីមង្គលការ** សមភាពច្បាប់អាពាហ៍ពិពាហ៍អាចផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចបានយ៉ាងប្រត្យក្ស។

សមភាពច្បាប់អាពាហ៍ពិពាហ៍នឹងជួយពង្រឹងកេរ្តិ៍ឈ្មោះរបស់កម្ពុជា ជាតំបន់គោលដៅដែលមានលក្ខណៈបើកចំហទូលាយ មានសុវត្ថិភាព និងមានភាពស្វាគមន៍ ដែលជាកត្តាមួយជួយជំរុញដល់បណ្តាប្រជាជនជ្រើសរើសធ្វើដំណើរមក។

**«សមភាពច្បាប់អាពាហ៍ពិពាហ៍មានឥទ្ធិពលជាវិជ្ជមានយ៉ាងច្រើនលើកេរ្តិ៍ឈ្មោះរបស់ប្រទេស [ហូឡង់] ដែលជាសញ្ញាបង្ហាញឱ្យឃើញនូវបរិស្ថានសង្គមប្រកបដោយសុវត្ថិភាពនិងមានបរិយាបន្ន។ ប្រសិនបើប្រទេសមួយមានសញ្ញាជាទីសុវត្ថិភាព និងជាប្រទេសដែលមានភាពស្វាគមន៍ផងនោះ វានឹងមានផលជាវិជ្ជមានចំពោះភ្ញៀវទេសចរដែលជាអ្នកស្រឡាញ់ភេទដូចគ្នា និងភ្ញៀវទេសចរដទៃទៀតផងដែរ ដូចជាស្ត្រី អ្នកធ្វើដំណើរកំសាន្តម្នាក់ឯង និងជាលក្ខណៈគ្រួសារ។»** នេះបើតាមសំដីរបស់លោក ឌីក ដឺ ហ្រ្គាហ្វ (Dirk De Graaff) ស្ថាបនិកសណ្ឋាគាររ៉ាំប៊ូថាន (Rambutan Hotels)

តាមបទពិសោធអន្តរជាតិបង្ហាញឱ្យឃើញថា កំណែទម្រង់បរិយាបន្នដូចជាសមភាពច្បាប់អាពាហ៍ពិពាហ៍អាចនាំឱ្យមានកំណើនចំនួនភ្ញៀវទេសចរ និងជំរុញឱ្យមានការចំណាយរបស់ភ្ញៀវទេសចរកាន់តែច្រើន បង្កើតការងារបានច្រើនបន្ថែមទៀតនៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍ និងធ្វើឱ្យគោលដៅទេសចរណ៍ដែលមានកិត្តិស័ព្ទកាន់តែប្រសើរ។

**«[តំបន់]គោលដៅ ដែលមានក្របខ័ណ្ឌច្បាប់ប្រកបដោយបរិយាបន្នជាពិសេសចំពោះសមភាពច្បាប់អាពាហ៍ពិពាហ៍ គឺមាន ភាពទាក់ទាញដល់ភ្ញៀវទេសចរជាអ្នកស្រឡាញ់ភេទដូចគ្នា រួមទាំងសម្ព័ន្ធមិត្តរបស់ពួកគេផងដែរ ដោយទទួលបាននូវអត្ថប្រយោជន៍ពីទស្សនៈយល់ឃើញវិជ្ជមានពីតំបន់គោលដៅ និងកសាងការជឿទុកចិត្តជាមួយនឹងទីផ្សារអន្តរជាតិ។»** ការលើកឡើងរបស់ អាមីន ហ្គាបបួច៍ (Amine Gabbouj) ប្រធានកម្មវិធីនៃមូលនិធិសមាគមទេសចរណ៍បុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រីអន្តរជាតិ (International Gay and Lesbian Travel Association (IGLTA) Foundation)

សមភាពច្បាប់អាពាហ៍ពិពាហ៍ក៏នឹងអាចនាំឱ្យប្រទេសកម្ពុជាចូលទៅក្នុងទីផ្សារតំបន់គោលដៅសម្រាប់ពិធីមង្គលការជាសកលផងដែរ ដែលជាផ្នែកមួយជួយបង្កើនតម្លៃនៃវិស័យទេសចរណ៍។

លទ្ធផលនៃអត្ថប្រយោជន៍ពីគំរូនៃសេណារីយ៉ូចង្អុលបង្ហាញរបស់យើងសម្រាប់ប្រទេសកម្ពុជានៅក្នុងកំឡុងពេលពីរឆ្នាំបន្ទាប់ពីមានការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍៖

**ចំនួន ភ្ញៀវទេសចរអន្តរជាតិបន្ថែម៖**
**+ ៦៧.០០០ - ៣៣៥.០០០នាក់**

**ប្រាក់ចំណូលបន្ថែមនៃវិស័យទេសចរណ៍៖**
**+ ៣៦ - ១៨០ លានដុល្លារអាមេរិក**

**ការទ្រទ្រង់ឱ្យមានការងារ៖**
**+ ៥.០០០ - ២៦.០០០កន្លែង**

**ទេសចរណ៍អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា៖**
**+ ០,៧ - ១០,៨ លានដុល្លារអាមេរិក**

## ២.ការទាក់ទាញវិនិយោគទុន និង ជំនាញទេពកោសល្យ

ក្រុមហ៊ុននិងវិនិយោគិនកម្រិតសកលលោក បង្កើនការប៉ាន់ប្រមាណលើបរិយាបន្នសង្គម ការបើកទូលាយ និង គុណភាពជីវិតនៅពេលដែលជ្រើសរើសទីកន្លែងសម្រាប់វិនិយោគ និងប្រតិបត្តិការ។ ភស្តុតាងពីការសិក្សាជាសកលយ៉ាងច្រើនបង្ហាញថា បរិយាបន្នអ្នក ស្រឡាញ់ភេទដូចគ្នា ជួយប្រទេសទាំងនោះឱ្យទាក់ទាញបាននូវការវិនិយោគផ្ទាល់ពីបរទេស ដែលមានទំនួលខុសត្រូវ។ សមភាពច្បាប់អាពាហ៍ពិពាហ៍ ទាំងជាបរិយាបន្នផ្ទាល់ និងទាំងជាសញ្ញានៃបរិយាបន្នអាចពង្រឹងលទ្ធភាពរបស់ប្រទេសមួយក្នុងការរក្សាទុកនិងទាក់ទាញជនដែលមានជំនាញទេពកោសល្យខ្ពស់ផងដែរ។

**«បរិយាបន្នអ្នកស្រឡាញ់ភេទដូចគ្នា អាចជំរុញកំណើនសេដ្ឋកិច្ច ហើយធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់ប្រទេសមួយក្នុងការផ្សារភ្ជាប់ទៅនឹងទីផ្សារសកល និងទាក់ទាញការវិនិយោគ។»** អូផេន ហ្វ័រ ប៊ិសនីស្ស (Open for Business)

ប្រទេសកម្ពុជាកំពុងធ្វើការយ៉ាងសកម្មក្នុងការពង្រីកសេដ្ឋកិច្ចឌីជីថលរបស់ខ្លួន ពង្រឹងនវានុវត្តន៍ និងអភិវឌ្ឍមូលធនមនុស្ស។ សមភាពច្បាប់អាពាហ៍ពិពាហ៍ អាចពង្រឹងគោលបំណងទាំងនេះដោយបញ្ជូននូវសញ្ញាដ៏ច្បាស់លាស់មួយទៅកាន់ទីផ្សារសកលថាប្រទេសកម្ពុជាស្វាគមន៍នូវជំនាញទេពកោសល្យចម្រុះ ហើយត្រូវបានបន្សីទៅនឹងក្តីរំពឹងទុករបស់ពាណិជ្ជកម្មបែបទំនើប។ ជារួម ភស្តុតាងទាំងអស់បានបង្ហាញថា តាមរយៈការទទួលយកសមភាពច្បាប់អាពាហ៍ពិពាហ៍មកអនុវត្តនៅក្នុងប្រទេសកម្ពុជា អាចពង្រឹងលទ្ធភាពប្រកួតប្រជែងរបស់ខ្លួន ដែលជាប្រទេសគោលដៅមួយសម្រាប់ការវិនិយោគ។

**«រដ្ឋាភិបាលចាត់ទុកសមភាព និងបរិយាបន្នសង្គម ជាចំណុចសំខាន់សម្រាប់យុទ្ធសាស្ត្ររក្សាទុក និងទាក់ទាញកម្មករនិយោជិតដែលមានជំនាញខ្ពស់។»** ឯកឧត្តម កត្តា អ៊ន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនមានជំនាញខ្ពស់ កំពុងរស់នៅនិងធ្វើការនៅឯបរទេសរួចស្រេចទៅហើយ ដើម្បីអាចរស់នៅក្នុងភាពជាខ្លួនឯងបាន ហើយរីករាយនឹងគុណភាពជីវិត។ សមភាពច្បាប់អាពាហ៍ពិពាហ៍អាចជួយធ្វើឱ្យអ្នកមានជំនាញទេពកោសល្យខ្ពស់វិលត្រឡប់មកធ្វើការ និងរស់នៅក្នុងប្រទេសខ្លួនវិញបាន ហើយគាំទ្រនូវមហិច្ឆតារបស់កម្ពុជាក្នុងការកសាងកម្លាំងពលកម្មមួយប្រកបដោយថាមវ័ន្ត និងនវានុវត្តន៍ដែលជាការត្រៀមខ្លួនជាស្រេចសម្រាប់អនាគត។

## ៣.ការបង្កើនវិស័យឧស្សាហកម្មពិធីមង្គលការ

ពិធីមង្គលការ គឺជាផ្នែកមួយដ៏មានតម្លៃនៅក្នុងវប្បធម៌របស់កម្ពុជា និងជាប្រភពដ៏សំខាន់មួយនៃប្រាក់ចំណូលសម្រាប់សហគ្រាសមីក្រូ ធុនតូច និងមធ្យម។ ការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ នឹងជួយបើកបង្ហាញនូវតម្រូវការជំនាញទេពកោសល្យសំខាន់ៗក្នុងចំណោមគូស្រករភេទដូចគ្នាដែលប្រាថ្នារៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់ផង និងតាមបែបប្រពៃណីវប្បធម៌ផង។

> គំរូនៃសេណារីយ៉ូចង្អុលបង្ហាញ កំណើនប្រាក់ចំណូលពីការរៀបពិធីមង្គលការក្នុងស្រុកនៅប្រទេសកម្ពុជា ក្នុងអំឡុងពេលពីរឆ្នាំបន្ទាប់ពីមានសមភាពច្បាប់អាពាហ៍ពិពាហ៍៖
> **+ ៤៦-១៣៩ លានដុល្លារអាមេរិក នៅក្នុងប្រាក់ចំណូលថ្មី**

ការចំណាយនេះមានលំហូរទៅលើថ្លៃទីតាំងរៀបចំពិធីមង្គលការអ្នករៀបចំម្ហូបអាហារ ក្រុមតន្ត្រី អ្នកតុបតែងផ្កា ជាងកាត់សំលៀកបំពាក់ ជាងថតរូប អ្នករៀបចំកម្មវិធី និងកន្លែង ស្នាក់នៅក្នុងស្រុក ដែលបង្កើតការងារ ព្រមទាំងពង្រឹង សេដ្ឋកិច្ច សហគមន៍។

គូស្រករភេទដូចគ្នាដែលបានផ្តល់កិច្ចសម្ភាស សម្រាប់ការសិក្សាស្រាវជ្រាវនេះបានពិពណ៌នាពីសារៈសំខាន់ដ៏ស៊ីជម្រៅផ្នែកប្រពៃណីវប្បធម៌នៃអាពាហ៍ពិពាហ៍៖ **«ការរៀបការគឺមានតម្លៃណាស់ ពុំមែនសម្រាប់តែបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកយើងចំពោះគ្នាទៅវិញទៅមកតែប៉ុណ្ណោះទេ វាថែមទាំងបង្ហាញពីការគោរពចំពោះវប្បធម៌ និងទំនៀមទម្លាប់របស់យើងផងដែរ។»** ការលើកឡើងរបស់លោកស្រី ជួប ចន្ទី អាយុ៥០ឆ្នាំ និងជាស្ត្រីស្រឡាញ់ស្ត្រីជនជាតិខ្មែរ ដែលកំពុងមានទំនាក់ទំនងភេទដូចគ្នា



## ៤.ការពង្រឹងគ្រួសារ

អាពាហ៍ពិពាហ៍ផ្តល់នូវក្របខ័ណ្ឌផ្នែកច្បាប់ ដែលការពារគ្រួសារ អាចជួយឱ្យមានផែនការហិរញ្ញវត្ថុរួមគ្នា និងកាត់បន្ថយភាពងាយរងគ្រោះនៅពេលដែលមានហេតុការណ៍តក់ស្លុតណាមួយកើតឡើងភ្លាមៗដោយឥតព្រាងទុក។ ការផាត់ចេញពីអាពាហ៍ពិពាហ៍ស្របច្បាប់ គឺជាការទុកឱ្យគូស្រករភេទដូចគ្នាគ្មានការការពារដោយច្បាប់ជាមូលដ្ឋាន រួមបញ្ចូលទាំងភាពពាក់ព័ន្ធនឹងអចលនទ្រព្យរួម កេរមរតក ស្មុំកូន និងអត្ថប្រយោជន៍សង្គមផ្សេងទៀត។

**«នៅពេលដែលពួកគេមិនអាចចុះសំបុត្រអាពាហ៍ពិពាហ៍បាន ពួកគេគឺបាត់បង់នូវអត្ថប្រយោជន៍នៃការការពារពីច្បាប់។»** នេះជាការលើកឡើងរបស់ លោកជំទាវ ញាណ សុចិត្រា អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍសង្គមនៃក្រសួងកិច្ចការនារី។

ការទទួលស្គាល់តាមផ្លូវច្បាប់ពង្រឹងនូវភាពជឿជាក់ផ្នែកហិរញ្ញវត្ថុ ជំរុញលើកទឹកចិត្តឱ្យមានការវិនិយោគរួមគ្នា និងពង្រឹងកិច្ចគាំពារ

ការទទួលស្គាល់តាមផ្លូវច្បាប់ពង្រឹងនូវភាពជឿជាក់ផ្នែកហិរញ្ញវត្ថុ ជំរុញលើកទឹកចិត្តឱ្យមានការវិនិយោគរួមគ្នា និងពង្រឹងកិច្ចគាំពារ
សង្គម។ សមភាពច្បាប់អាពាហ៍ពិពាហ៍អាចផ្តល់នូវកំណើនរូបវន្តផ្នែកសង្គមនិងសេដ្ឋកិច្ចសម្រាប់គ្រួសាររបស់ប្រជាជនកម្ពុជា ដោយពង្រឹងសន្តិសុខ កាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងពង្រឹងភាពធន់របស់គ្រួសារសម្រាប់រយៈពេលវែង។

ភស្តុតាងអន្តរជាតិបង្ហាញថា អាពាហ៍ពិពាហ៍ស្របច្បាប់ពង្រឹងសន្តិសុខហិរញ្ញវត្ថុ និងបង្កើនការចំណាយ ដែលត្រូវបានស្គាល់ថាជា «គុណសម្បត្តិអាពាហ៍ពិពាហ៍» ។

គំរូនៃសេណារីយ៉ូចង្អុលបង្ហាញពីកំណើននៅក្នុងការចំណាយរបស់គ្រួសារ ក្នុងអំឡុងពេលពីរឆ្នាំបន្ទាប់ពីការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍នៅប្រទេសកម្ពុជា៖

**+ ០,៣ - ៤,៥ លានដុល្លារអាមេរិក**



# ៥.ការធ្វើឱ្យប្រសើរឡើង ផ្នែកសុខភាព ផលិតភាព និងពាណិជ្ជកម្ម

**«បរិយាបន្ននឹងអាចនាំឱ្យមានការបង្កើនផលិតភាពនៃកម្លាំងពលកម្មដែលមានស្រាប់ ធ្វើឱ្យមានការវិនិយោគទុកកាន់តែច្រើនលើមូលធនមនុស្ស និងមានសុខភាពល្អកាន់តែប្រសើរឡើង។»** តាមការលើកឡើងរបស់ លី ប៉ែដហ្គេត (M.V. Lee Badgett) សេដ្ឋវិទូអន្តរជាតិ

ការផាត់ចេញគឺបណ្តាលឱ្យមានការខាតបង់តម្លៃសេដ្ឋកិច្ចដែលអាចវាស់វែងបាន។ សមភាពច្បាប់អាពាហ៍ពិពាហ៍អាចកាត់បន្ថយបាននូវភាពតានតឹងផ្លូវចិត្តជាច្រើន ដោយបង្កើនសុវត្ថិភាពផ្នែកផ្លូវចិត្ត ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់កម្មករនិយោជិត និងពង្រឹងលទ្ធផលអាជីវកម្ម។ លទ្ធផលទាំងនេះត្រូវបានកត់ត្រាទុកជាឯកសារដ៏ល្អនៅលើសកលលោក ហើយត្រូវបានធ្វើការឆ្លុះបញ្ចាំងយ៉ាងមុតមាំនៅក្នុងកិច្ចសម្ភាសជាមួយនិយោជក និងអ្នកតាក់តែងគោលនយោបាយកម្ពុជា។

ការផាត់ចេញនិងការរើសអើងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សុខភាពផ្លូវចិត្ត លទ្ធផលនៃការសិក្សា និងការចូលរួមនៅក្នុងកម្លាំងពលកម្ម។ ការសិក្សាស្រាវជ្រាវរបស់កម្ពុជាបង្ហាញថា បច្ចុប្បន្ននេះ អ្នកស្រឡាញ់ភេទដូចគ្នាកំពុងប្រឈមនឹងបញ្ហាសុខភាពផ្លូវចិត្តដ៏គួរឱ្យកត់សម្គាល់ ដែលភាគច្រើនគឺបណ្តាលមកពីបទពិសោធជីវិតនៃការរើសអើង និងការបំពាក់ស្លាកស្នាមទុសយស ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ **«សមភាពច្បាប់អាពាហ៍ពិពាហ៍អាចជួយមនុស្សឱ្យមានអារម្មណ៍ថាមានសេរីភាពជាងមុន មានការជឿជាក់ជាងមុន...វាអាចជួយបង្កើតនូវអារម្មណ៍នៃការទទួលយក និងអារម្មណ៍ស្កប់ស្កល់។»** នេះជាការលើកឡើងរបស់គ្លីនិកផ្នែកអ្នកចិត្តសាស្ត្រកម្ពុជា

ការប្រើប្រាស់វិធីសាស្ត្រដែលបានទទួលស្គាល់ជាអន្តរជាតិមកអនុវត្តនៅកម្ពុជា៖

គំរូនៃសេណារីយ៉ូចង្អុលបង្ហាញ៖ ការខាតបង់ផលិតភាពប្រចាំឆ្នាំដោយសារតែការធ្លាក់ទឹកចិត្តផ្សារភ្ជាប់នឹងការផាត់ចេញអ្នកស្រឡាញ់ភេទដូចគ្នា៖
៨ - ២៤ លានដុល្លារអាមេរិក

គំរូនៃសេណារីយ៉ូចង្អុលបង្ហាញ៖ ការខាតបង់ផលិតភាពប្រចាំឆ្នាំដោយសារតែការរើសអើងនៅកន្លែងធ្វើការ៖
១៥៥ លានដុល្លារអាមេរិក

សមភាពច្បាប់អាពាហ៍ពិពាហ៍អាចនឹងជំរុញបរិយាបន្នសង្គម តាមរយៈការបញ្ជាក់ថា គ្រួសារអ្នកស្រឡាញ់ភេទដូចគ្នាគឺមានសិទ្ធិស្មើគ្នានៅក្នុងផ្លូវច្បាប់។ វាមានសក្តានុពលក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខភាពផ្លូវចិត្ត ពង្រឹងស្ថិរភាពគ្រួសារ និងដកចេញនូវប្រភពសំខាន់ៗដែលនាំឱ្យមានការតានតឹងផ្លូវចិត្ត ពោលគឺជួយឱ្យអ្នកស្រឡាញ់ភេទដូចគ្នាអាចរួមចំណែកបានពេញលេញជាងមុនចំពោះអាយុជីវិតសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

ចំពោះសេដ្ឋកិច្ចទូទៅ សមភាពច្បាប់អាពាហ៍ពិពាហ៍ក៏ពង្រឹងភាពប្រកួតប្រជែង និងនវានុវត្តន៍ផងដែរ។ ដូចលោកបណ្ឌិត ប៊ែន លី (Dr Ben Li) ស្ថាបនិក និងអគ្គនាយក អឺរបាន វិលេច (Urban Village) និង ហ្វេកធឺរីភ្នំពេញ (Factory Phnom Penh) បានធ្វើជាម្ចាស់ផ្ទះ និងគាំទ្រកម្មវិធីអបអរមោទនភាព នៅរាជធានីភ្នំពេញ ដោយបានគូសបញ្ជាក់ថា អ្នកស្រឡាញ់ភេទដូចគ្នាគឺជាអ្នកចូលរួមចំណែកយ៉ាងសកម្មនៅក្នុងវិស័យនានាដែលទើបនឹងលេចឡើង ដូចជាឧស្សាហកម្មបែបច្នៃប្រឌិតនិងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចដែលទើបបង្កើតឡើង៖ **«ការទទួលយកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាអាចនាំមក នូវភាពច្នៃប្រឌិត នវានុវត្តន៍ និងជួយលើកស្ទួយកិត្តិស័ព្ទរបស់កម្ពុជា។»**

មានភស្តុតាងដ៏រឹងមាំជាសកលដែលបញ្ជាក់ថា ក្រុមហ៊ុនដែលមានបរិយាបន្នអ្នកស្រឡាញ់ភេទដូចគ្នា គឺមានដំណើរការល្អជាងក្រុមហ៊ុនផ្សេងទៀត។ ការសិក្សាទាំងនោះដែលបានសង្ខេបដោយ អូផេន ហ្វ័រ ប៊ីសនីស្ស (Open for Business) បង្ហាញថា ក្រុមហ៊ុនដែលមានគោលនយោបាយបែបបរិយាបន្នគឺទទួលបានប្រាក់ចំណេញ មានផលិតភាព និងនវានុវត្តន៍ខ្ពស់ជាង ក៏ដូចជាមានភាពប្រសើរជាងក្នុងការទាក់ទាញអ្នកមានជំនាញទេពកោសល្យ ហើយមានចំនួនបុគ្គលិកលាឈប់តិចតួច។ នៅពេលដែលក្រុមហ៊ុនធ្វើប្រតិបត្តិការក្នុងបរិយាកាសបែបបរិយាបន្ន រួមទាំងប្រទេសដែលបានទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ផងនោះ ក្រុមហ៊ុនទាំងនោះគឺស្ថិតនៅក្នុងមុខងារល្អប្រសើរជាងក្នុងការទទួលបានអត្ថប្រយោជន៍ទាំងនេះ។

**«ពិតប្រាកដណាស់ ដែលមុខជំនួញមួយទទួលបានអត្ថប្រយោជន៍គឺនៅពេលដែលទម្ងន់នៃសម្ពាធរបស់ពួកគេត្រូវបានដកចេញ ជារួមទាំងគំនិត និងការរួមចំណែកគឺរមែងជាចំណុចប្រសើរជាងនិងធំជាង។»** ការលើកឡើងរបស់ ជៀប ពុទ្ធិកា នាយក សៀមរាបហោស៍ (Siem Reap House)

**នៅពេលចាប់យកបរិយាបន្ន ប្រទេសកម្ពុជានឹងបើកបង្ហាញនូវសក្តានុពលរបស់ប្រជាជនកម្ពុជាទាំងអស់គ្នា និងបោះជំហានដោយទំនុកចិត្ត ទៅកាន់អនាគតមួយប្រកបដោយសមធម៌ និងភាពរុងរឿង។**

## អត្ថប្រយោជន៍ជាតួលេខ

ការប៉ាន់ស្មានសរុបចំពោះកំណើនសេដ្ឋកិច្ចដែលអាចកើនឡើងនៅក្នុងអំឡុងពេលពីរឆ្នាំនៃការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍របស់កម្ពុជា (សញ្ញាចង្អុលបង្ហាញ) អាចកើនប្រហែលជា**៨៣ - ៣៣៤ លានដុល្លារ**អាមេរិក ដោយផ្តោតលើការចំណាយបន្ថែមនៅក្នុងវិស័យទេសចរណ៍ការរៀបពិធីមង្គលការ និងការចំណាយរបស់គ្រួសារ។*

*នេះមិនរាប់បញ្ចូលការប៉ាន់ស្មានប្រចាំឆ្នាំដែលដកចេញដាច់ដោយឡែកពីការខាតបង់ផលិតភាពពាក់ព័ន្ធនឹងសុខភាព និងការរើសអើងនៅកន្លែងធ្វើការ។





សូមស្វែងរកព័ត៌មានលម្អិតបន្ថែមនៅក្នុងសេចក្តីសង្ខេបរបាយការណ៍សិក្សាស្រាវជ្រាវទាំងមូលរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា និងអង្គការវេទិកាអនាគត៖ «ការបើកបង្ហាញសក្តានុពល - អត្ថប្រយោជន៍សេដ្ឋកិច្ចនៃសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ប្រទេសកម្ពុជា» (ឆ្នាំ២០២៦)។

អង្គការវេទិកាអនាគត (Future Forum) គឺជាក្រុមជំនាញការ (think tank) ឯករាជ្យមួយ ដែលធ្វើការងារផ្តោតលើការបណ្តុះអ្នកគិតថ្មីៗ និងគិតដើម្បីប្រទេសកម្ពុជា។ www.futureforum.asia

អង្គការសហគមន៍ឥន្ទធនូកម្ពុជា (RoCK) គឺជាអង្គការមិនមែនរដ្ឋាភិបាលនៅប្រទេសកម្ពុជា ដែលធ្វើការងារផ្តោតលើការគាំទ្រសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា។ ដោយមានកិច្ចសហការរួមគ្នាជាមួយដៃគូ សង្គមស៊ីវិលមួយចំនួន RoCKបានដឹកនាំយុទ្ធនាការ «ខ្ញុំទទួលយក» ដើម្បីជំរុញនូវវឌ្ឍនភាពនៃការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍នៅកម្ពុជា។ www.rockcambodia.org